នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Apr-2019, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Phillip RAPOZA
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោកស្រី Doreen CHEN
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាជំទាស់នឹងការពន្យារពេលវេលាយ៉ាងវែង និងការបន្ថែមចំនួនទំព័រកំណត់យ៉ាងច្រើនដែលបានស្នើឡើងដោយ នួន ជា និង ខៀវ សំផន[1]។ ការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ដូចដែលបានស្នើ មិនអាចអនុញ្ញាតបានទេនៅក្នុងកាលៈទេសៈនេះ ហើយជាលទ្ធផលវាអាចនឹងធ្វើឲ្យមានការពន្យារពេលដល់កិច្ចដំណើរការនីតិវិធីមិនចាំបាច់។

2. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបន្ថែមពេលវេលារហូតដល់៤៥ថ្ងៃ ដែលបង្កើនចំនួនថ្ងៃសរុបរហូតដល់៧៥ថ្ងៃនោះ គឺរឿងសមហេតុផល ចំណែកការកំណត់ចំនួន៣០ទំព័របច្ចុប្បន្ន គឺជាការគ្រប់គ្រាន់ហើយសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។

## II. ប្រវត្តិនីតិវិធី

3. សាលក្រមសំណុំរឿង០០២/០២ បានចេញនូវសេចក្តីសង្ខេប កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[2]។ នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញអំពីការសម្រេចផ្លូវច្បាប់របស់ខ្លួន ស្តីពីគោលនយោបាយរបស់ បកក និងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ ទាក់ទងនឹងសហករណ៍ និងការដ្ឋាននានា មន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្ស ការកំណត់គោលដៅចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ និងការកំណត់អំពីការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញអំពីឧក្រិដ្ឋកម្មដែលខ្លួនមានភស្តុតាងបញ្ជាក់ហួសពីវិមតិសង្ស័យ និងឧក្រិដ្ឋកម្មដែលខ្លួនមិនផ្តន្ទាទោស[3]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានពន្យល់ផងដែរអំពីទម្រង់នៃការទទួលខុសត្រូវដែល នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវ និងទម្រង់នៃការទទួលខុសត្រូវដែលមិនអាចពិចារណាបានទៅតាមបទដ្ឋាននៃលក្ខខណ្ឌតម្រូវ[4]។

---

[1] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ("សំណើរបស់ ខៀវ សំផន")។ ឯកសារ **F40/1.1** សំណើបន្ទាន់លើទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ("សំណើរបស់ នួន ជា")។

[2] សេចក្តីសង្ខេបសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សេចក្តីសង្ខេបសាលក្រមសាលាដំបូង")។

[3] សេចក្តីសង្ខេបសាលក្រមសាលាដំបូង ទំព័រ ៥-១៩, ២៩-៣១។

[4] សេចក្តីសង្ខេបសាលក្រមសាលាដំបូង ទំព័រ ១៩-២៧។

4. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមដែលមានសម្អាងហេតុពេញលេញរបស់ខ្លួន[5]។

5. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ នួន ជា បានដាក់សំណើរបស់គាត់ដោយសុំបន្ថែមពេលវេលាចំនួន ១៥០ថ្ងៃ (សរុបឡើងដល់១៨០ថ្ងៃ) និងបន្ថែមទំព័រចំនួន៧០ទំព័រ (សរុបឡើងដល់១០០ទំព័រ) ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[6] ដោយគាត់បង្ហាញថា នេះគ្រាន់តែជាការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់លើកទីមួយប៉ុណ្ណោះ សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[7]។ នៅថ្ងៃដដែល ខៀវ សំផន បានស្នើសុំបន្ថែមពេលវេលាជាសរុបរហូតដល់២៤០ថ្ងៃ និងចំនួន១០០ទំព័រជាភាសាបារាំង សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[8]។

## III. ចម្លើយតប

### *(i) ទំហំ ភាពស្មុគស្មាញ និងនវោត្បន្ននៃសាលក្រមសាលាដំបូងសំណុំរឿង០០២/០២*

6. សហព្រះរាជអាជ្ញាទទួលស្គាល់ថា មេធាវីការពារក្តីនិយាយត្រូវដែលបានចង្អុលបង្ហាញថា សាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០២ គឺវែង និងស្មុគស្មាញហើយមានការពាក់ព័ន្ធនឹងបញ្ហានីត្យានុកូលប្លែកថ្មីៗ។ តែយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថាថ្វីបើកត្តាទាំងនេះគួរត្រូវបានពិចារណា តែមិនអាចជាយុត្តិកម្មដល់ការពន្យារពេលដ៏វែងមិនធម្មតា ដូចបានស្នើដោយមេធាវីការពារក្តីឡើយ។

7. ជាឧទាហរណ៍ នួន ជា ចង្អុលពីទំហំនៃសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០២ បានឲ្យដឹងថា “ប្រសិនបើចំនួនទំព័រនៅក្នុងសាលក្រមនេះត្រូវបានពិចារណាថា គឺជាវិធានការដ៏សំខាន់បំផុតមួយនៃប្រវែងពេលវេលាត្រូវការសម្រាប់ការត្រៀមរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ” នោះប្រវែងពេលវេលាដែលគួរផ្តល់ឲ្យមេធាវីការពារក្តីគឺ១៩០ថ្ងៃ[9]។ ប៉ុន្តែ សវនាការអន្តរជាតិដទៃទៀតដែល នួន ជា បានពឹងផ្អែក បង្ហាញឲ្យឃើញថា បើតាមទម្លាប់នៃការអនុវត្ត សំណើរបស់គាត់គ្មានការគាំទ្រទេ។ ជាឧទាហរណ៍ សាលក្រមសាលាដំបូងក្នុងរឿងក្តី *Karadžić* ដែលមានប្រវែង ២,៦១៥ទំព័រ គាត់បាន

[5] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

[6] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ១។

[7] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៣៥។

[8] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤២។

[9] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៤៣។

ទទួលការពន្យារពេលរហូតដល់៩០ថ្ងៃ (សរុប១២០ថ្ងៃ)[10]; សាលក្រមសាលាដំបូងក្នុងរឿងក្តី *Mladić* ដែលមានប្រវែង២,៤៧៧ទំព័រ គាត់បានទទួលការពន្យារពេលរហូតដល់៩០ថ្ងៃ (សរុប១២០ថ្ងៃ)[11]; ចំណែកសាលក្រមសាលាដំបូងក្នុងរឿងក្តី *Taylor* ដែលមានប្រវែង២,៤៧៨ទំព័រ គាត់បានទទួលការពន្យារពេលរហូតដល់៧១ថ្ងៃ (សរុប៨៥ថ្ងៃ)[12]។ សាលក្រមនិមួយៗទាំងនេះសុទ្ធតែវែងជាងសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០២ ហើយសាលក្រមនិមួយៗពាក់ព័ន្ធតែជាមួយនឹងជនជាប់ចោទតែម្នាក់ប៉ុណ្ណោះ។

8. ការពឹងផ្អែករបស់ នួន ជា និង ខៀវ សំផន នៅលើផែនការបញ្ចប់របស់ អ.វ.ត.ក និងការផ្តល់សម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង អំពីប្រវែងពេលវេលាដែលបានប្រើប្រាស់ដើម្បីចេញសាលក្រម គឺធ្វើឡើងដោយចោះៗ[13]។ សំណើទាំងពីរទាត់ចោលសេចក្តីយោងរបស់អង្គជំនុំជម្រះសាលាដំបូងនៅលើបញ្ហាបុគ្គលិក និងការបកប្រែ - ដែលវាអត់ពាក់ព័ន្ធនឹងទំហំនៃសំណុំរឿងទេ - ពេលធ្វើការពន្យល់អំពីការស្ទង់មើលទៅលើពេលវេលាដែលត្រូវការសម្រាប់ការចេញសាលក្រម[14]។

### *(ii) ការខ្វះខាតធនធានដែលបានអះអាងសម្រាប់ការការពារក្តី*

9. ប្រហែលជានៅចន្លោះពេលនៃការដាក់សារណាសន្និដ្ឋានស្ពាពរដែលបានកែសម្រួលនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ និងសេចក្តីសង្ខេបសាលក្រមនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ក្រុមរបស់ នួន ជា មានសមាសភាព

---

[10] *រដ្ឋអាជ្ញា ទល់នឹង* *Karadžić*, IT-95-5/18-T, សាលក្រម ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦។ *រដ្ឋអាជ្ញា ទល់នឹង* *Karadžić*, MICT-13-55-A សេចក្តីសម្រេចលើញត្តិស្នើសុំបន្ថែមពេលវេលាដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ទំព័រ២ ("សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលាលើកទីមួយរបស់ *Karadžić*")។ *រដ្ឋអាជ្ញា ទល់នឹង* *Karadzić*, MICT-13-55-A សេចក្តីសម្រេចលើញត្តិស្នើសុំបន្ថែមពេលវេលាបន្ថែមទៀតដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ទំព័រ ៣-៤ (សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលាលើកទីពីរ ក្នុងរឿងក្តី *Karadžić*")។

[11] *រដ្ឋអាជ្ញា ទល់នឹង* *Mladić*, IT-09-92-T សាលក្រម ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។ *រដ្ឋអាជ្ញា ទល់នឹង* *Mladić*, MICT-13-56-A សេចក្តីសម្រេចលើញត្តិស្នើសុំបន្ថែមពេលវេលាដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ទំព័រ២ ("សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលាក្នុងរឿងក្តី *Mladić*")។

[12] *រដ្ឋអាជ្ញា ទល់នឹង* *Taylor*, SCSL-03-01-T, សាលក្រម, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២។ *រដ្ឋអាជ្ញា ទល់នឹង* *Taylor*, SCSL-03-01-A សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំបន្ថែមពេលវេលា ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ទំព័រ៣ ("សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលាក្នុងរឿងក្តី Taylor") ទំព័រ ២-៣។

[13] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៣៩។ ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៣។

[14] ផែនការបញ្ចប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី១៧) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣២-៣៣។

មេធាវីការពារក្តី២រូប និងកុងស៊ុលតង់ធ្វើការពេញម៉ោង៤រូប[15] ហើយចំណែកឯក្រុម ខៀវ សំផន វិញ មានមេធាវីការពារក្តី២រូប និងកុងស៊ុលតង់២រូបដែរ[16]។ ដូច្នេះ ក្រុមមេធាវីការពារក្តីនិមួយៗមានពេលវេលាជាងមួយឆ្នាំ ដើម្បីកំណត់អត្តសញ្ញាណបញ្ហានីតិវិធី ឬភ័ស្តុតាងណាមួយដែលទំនងជាមានបញ្ហា ឬដែលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខណាមួយដែលអាចមាន ដែលអាចធ្វើជាសេចក្តីយោងប្រឆាំងនឹងសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង។ តាមការពិត នួន ជា និយាយថាគាត់បាន "កំណត់អត្តសញ្ញាណរួចហើយ យ៉ាងហោចណាស់ក៏មានសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរចំនួន៥៦ ដែលមានកំហុសអាចប្តឹងសាទុក្ខបាន"[17] ខណៈដែល ខៀវ សំផន បានកត់សម្គាល់ថា មានសេចក្តីសម្រេចជាលាយល័ក្ខណ៍អក្សរជាង២៩៥ ដោយមិនរាប់បញ្ចូលសេចក្តីសម្រេចផ្ទាល់មាត់ នៅក្នុងអំឡុងនៃសវនាការសំណុំរឿង០០២/០២[18]។ ដូច្នេះច្បាស់ណាស់ថាទាំង នួន ជា និងទាំង ខៀវ សំផន សុទ្ធតែមានពេលវេលាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីកំណត់អត្តសញ្ញាណ និងវិភាគទៅលើសេចក្តីសម្រេចណាមួយដែលពួកគាត់ចង់ប្តឹងសាទុក្ខ[19]។

10. ជាការបន្ថែម ថ្វីបើមានការប្រឹងប្រែងរបស់ នួន ជា ដើម្បីបន្ធូរបន្ថយខ្លឹមសារ និងសារៈសំខាន់នៃសេចក្តីសង្ខេបសាលក្រមដែលបានចេញនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ តាមរយៈការយោងទៅរកសេចក្តីសង្ខេបសាលក្រមថា "មិនផ្លូវការ"ក៏ដោយ[20] ក៏សេចក្តីសង្ខេបនេះអនុញ្ញាតឲ្យគូភាគីទាំងអស់ អាចចាប់ផ្តើមធ្វើការត្រៀមរៀបចំបណ្តឹងសាទុក្ខបាន តាមរយៈការចង្អុលបង្ហាញនូវផ្នែកណានៃទ្រឹស្តីក្នុងករណីរបស់ខ្លួនដែលមិនបានទទួលយក[21]។

11. ចាប់តាំងពីពេលចេញសេចក្តីសង្ខេបសាលក្រម ក្រុម នួន ជា (គិតត្រឹមពេលចុងក្រោយបំផុតគឺថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩) មានមេធាវីការពារក្តី២រូប អ្នកវិភាគភ័ស្តុតាងជាន់ខ្ពស់ម្នាក់ និងកុងស៊ុលតង់ធ្វើការពេញម៉ោង និងពាក់កណ្តាលម៉ោងរហូតដល់ប្រាំមួយនាក់[22] ហើយក្រុមរបស់ ខៀវ សំផន វិញ (គិតត្រឹមពេលចុងក្រោយបំផុតគឺថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨) មានមេធាវីការពារក្តី២រូប និងកុងស៊ុលតង់

---

[15] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៥។

[16] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៨។

[17] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៤៩។

[18] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២០។

[19] *សូមមើល* ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៤៨-៤៩, ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ២៣ សម្រាប់ការអះអាងទាក់ទងនឹងកង្វះបណ្តឹងសាទុក្ខបន្ទាន់បង្ខំប្រឆាំងសេចក្តីសម្រេចរបស់សាលាដំបូង។

[20] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៣។ សូមមើលផងដែរ កថាខណ្ឌ ៤។

[21] *ដូចពីនេះ* ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៥៧។

[22] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៦-៧។

៥នាក់[23]។ អាស្រ័យហេតុនេះ តាំងពីមុនចេញសាលក្រមសាលាដំបូងដែលមានសម្អាងហេតុពេញលេញ ក្រុមមេធាវីការពារក្ដី នួន ជា មានបុគ្គលិក៩នាក់ ហើយក្រុមរបស់ ខៀវ សំផន វិញមានបុគ្គលិក៧នាក់។

12. ខៀវ សំផន តាមរយៈអង្គភាពគាំពារការការពារក្ដី ក៏បានស្នើឲ្យមានការពង្រីកថវិកាដើម្បីឲ្យមានកុងស៊ុលតង់៧នាក់ ដែលនឹងធ្វើឲ្យចំនួនបុគ្គលិកក្នុងក្រុមរបស់គាត់ឡើងដល់ប្រាំបួននាក់[24]។ ធ្វើដូច្នេះគឺដើម្បីឲ្យក្រុមមេធាវីការពារក្ដី ខៀវ សំផន មានទំហំប៉ុនគ្នានឹងក្រុមសវនាការរបស់គាត់ដែរ *បន្ទាប់ពី* ក្រុមរបស់ខ្លួនទទួលបានមូលនិធិបន្ថែមសម្រាប់ជួលកុងស៊ុលតង់ពីរនាក់ សម្រាប់ការងារត្រួតពិនិត្យលើការដាក់បង្ហាញឯកសារ[25]។ ដូច្នេះ ខៀវ សំផន ហាក់ដូចជាកំពុងធ្វើផែនការសម្រាប់ធនធានក្រុមរបស់គាត់ ដោយប្រៀបធៀបនឹងក្រុមខ្លួនក្នុងពេលមួយនៃសវនាការដ៏មមាញឹក ជាជាងបណ្ដឹងសាទុក្ខដែលយើងកំពុងតែផ្ដោតការយកចិត្តទុកដាក់នេះ[26]។

13. ផ្ទុយទៅវិញ ការិយាល័យសហព្រះរាជអាជ្ញាមានមេធាវីតែពីរបីនាក់ប៉ុណ្ណោះ គឺតិចជាងមេធាវីដែលមានក្នុងពេលដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន និងមានមេធាវីដែលកំពុងធ្វើការលើបណ្ដឹងសាទុក្ខនេះតិចជាងក្រុមមេធាវីការពារក្ដីទាំងពីរ រួមបញ្ចូលគ្នារបស់ នួន ជា និង ខៀវ សំផន។ ការណ៍នេះបើទោះបីជាការពិត សហព្រះរាជអាជ្ញាត្រូវធ្វើការងារផ្សេងទៀតក្នុងពេលដំណាលគ្នាលើបណ្ដឹងឧទ្ធរណ៍មុនសវនាការនៃសំណុំរឿង ០០៣, ០០៤ និង ០០៤/០២ នៅក្នុងអំឡុងពេលនៃបណ្ដឹងសាទុក្ខនៃសំណុំរឿង០០២/០២ នេះក៏ដោយ។

### *(iii) ការប្រៀបធៀបរវាងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង០០២/០២ និងរឿងក្ដីអន្តរជាតិផ្សេងទៀត*

14. ខៀវ សំផន លើកឡើងថា ការប្រៀបធៀបជាមួយនឹងរឿងក្ដីអន្តរជាតិផ្សេងទៀត គឺមានភាពពាក់ព័ន្ធតិចតួច ជាពិសេស ដោយសារតែរយៈពេលផ្លូវច្បាប់របស់ អ.វ.ត.ក និងលក្ខណៈនៃការបំបែកសំណុំរឿងក្នុងសំណុំរឿង០០២ នេះ[27]។ ទោះជាយ៉ាងណា ទោះបីជាបញ្ហានេះពិតជាធ្វើឲ្យ អ.វ.ត.ក *ជាតុលាការ*ថ្មីធៀបទៅនឹងតុលាការអន្តរជាតិផ្សេងទៀតក្ដី វាមិនបានធ្វើឲ្យបណ្ដឹងសាទុក្ខនៃសំណុំ

---

[23] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣០។

[24] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣០។

[25] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣១ តារាង។

[26] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣២។

[27] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៨។

រឿង០០២/០២ មិនអាចឃើញខុសគ្នាពីរឿងក្តីអន្តរជាតិធំៗផ្សេងទៀតទេ។ ការពិតនោះ គឺថាបន្ទាប់ពីមានសវនាការពីរ និងបណ្តឹងសាទុក្ខពីរ ច្បាប់ជាធរមាននៅ អ.វ.ត.ក ត្រូវបានដោះស្រាយក្នុងកម្រិតដ៏ទូលំទូលាយមួយ។ ស្រដៀងគ្នានេះដែរ បញ្ហានៃការបំបែកសំណុំរឿងត្រូវបានប្តឹង និងត្រូវបានប្តឹងឡើងវិញ[28] ដូច្នេះសារៈសំខាន់របស់វាដែលជាបញ្ហាមួយនៅក្នុងបរិបទនៃបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០២ គឺមានតិចតួចបំផុត។

15. ផ្ទុយទៅវិញ នួន ជា ស្វែងរកការគាំទ្រសម្រាប់សំណើសុំបន្ថែមពេលវេលារបស់ខ្លួន ដោយឈរលើមូលដ្ឋានដែលថា រឿងក្តីដែលមានជនជាប់ចោទច្រើនមកពីតុលាការ ICTY និង ICTR មានសាលក្រមតូចជាងសំណុំរឿង០០២/០២ - ហើយហេតុដូច្នេះ សាលក្រមមានចំនួនទំព័រតិចជាងពាក់ព័ន្ធទៅនឹងជនជាប់ចោទនីមួយៗ - ហើយនៅតែទទួលបានការពន្យារពេលចន្លោះពី៣០ ទៅ៦០ថ្ងៃ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[29]។ ទោះជាយ៉ាងណា ផ្អែកលើតក្កវិជ្ជានេះ រឿងក្តីដែលមានជនជាប់ចោទតែម្នាក់នៅកម្រិតអន្តរជាតិ ដែលត្រូវបានពឹងផ្អែកលើដោយ នួន ជា ដែរនោះ - ដែលនៅក្នុងនោះរាល់ទំព័រទាំងអស់នៃសាលក្រមពាក់ព័ន្ធទៅនឹងជនជាប់ចោទ - បង្ហាញថា នួន ជា និង ខៀវ សំផន គួរទទួលបានការបន្ថែមតិចជាងការបន្ថែមដែលផ្តល់ឲ្យ *Mladić* (៩០ថ្ងៃ)[30] *Karadžić* (៩០ថ្ងៃ)[31] ឬ *Taylor* (៧១ថ្ងៃ)[32] - ដែលទាំងអស់នេះគឺជារឿងក្តីដែលមានសាលក្រមវែងជាងសំណុំរឿង០០២/០២។

## *(iv) ការបន្ថែមចំនួនទំព័រកំណត់ដែលបានស្នើសុំ*

16. ជាក់ស្តែង ខណៈដែល នួន ជា ផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/១ ដើម្បីបន្ថែមពេលវេលាសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ភាគីនានា ដោយផ្អែកលើប្រវែងនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះ[33] គាត់មើលរំលងចំណុចដែលអង្គជំនុំជម្រះតុលាការកំពូលមិនបានបន្ថែមចំនួនទំព័រ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា

---

[28] សូមមើល *ឧទាហរណ៍* ឯកសារ **F36** សំណុំរឿង០០២/០១ សាលដីកាបណ្តឹងសាទុក្ខ កថាខណ្ឌ២២៤, ២២៨, ២៣៦, ៩០៨ ជើងទំព័រ ១, ៥៦០។

[29] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ ៤៧, ៤៥។

[30] *សេចក្តីសម្រេចលើការបន្ថែមក្នុងរឿងក្តី Mladić* ទំព័រ ២។

[31] សេចក្តីសម្រេចទីមួយលើការបន្ថែម *ក្នុងរឿងក្តី Karadžić* ទំព័រ២។ សេចក្តីសម្រេចទីពីរលើកការបន្ថែម *ក្នុងរឿងក្តី Karadžić* ទំព័រ ៣-៤។

[32] សេចក្តីសម្រេចលើការបន្ថែម ក្នុងរឿងក្តី *Taylor* ទំព័រ២-៣។

[33] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ៣៧។

សំណើសុំចំនួនទំព័របន្ថែមគឺមិនចាំបាច់ឡើយ ដោយសារតែ "សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខគឺកម្រិតត្រឹមតែការបញ្ជាក់ ឬគ្រាន់តែពន្យល់ត្រួសៗ អំពីការលើកឡើងនូវកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចនេះមោឃៈ និងការលើកឡើងនូវកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ហើយពុំតម្រូវឱ្យមានការលើកឡើងនូវទឡ្ហីករណ៍ ឬសម្អាងផ្លូវច្បាប់នានា ដើម្បីគាំទ្រឡើយ"[34]។ ផ្ទុយទៅវិញ នួន ជា ស្វែងរកការគាំទ្រពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានបន្ថែមចំនួនទំព័រកំណត់សម្រាប់*សារណាបណ្តឹងសាទុក្ខ* មិនមែនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខឡើយ[35]។

17. ជាងនេះទៀត ខណៈដែល នួន ជា ផ្អែកលើការប្រៀបធៀបមួយទៅនឹងសំណុំរឿងនានាមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ទាក់ទងទៅនឹងការបន្ថែមពេលវេលាកំណត់[36] គាត់មើលរំលងរបៀបដែលរឿងក្តីទាំងនេះមិនគាំទ្រការបន្ថែមចំនួនទំព័រកំណត់ដ៏ច្រើន សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលគាត់ស្នើសុំ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលបានដាក់ក្នុងសំណុំរឿងនានាដែលគាត់ដកស្រង់ ជាឧទាហរណ៍មាន៖ ៣២ទំព័រ ក្នុងរឿងក្តី *Mladić*[37] ១៦ទំព័រក្នុងរឿងក្តី *Karadžić*[38] ២២ទំព័រ ក្នុងរឿងក្តី *Gvero* (ផ្នែក *Popović និងគូកន*)[39] ១២ទំព័រ ក្នុងរឿងក្តី *Pavković* (ផ្នែក *Sainović និងគូកន*)[40] និង ៥៦ទំព័រ ក្នុងរឿងក្តី *Ntahobal* (ផ្នែក *Nyiramasuhuko និងគូកន*)[41]។

---

[34] ឯកសារ **F3/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[35] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ៣៧។

[37] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ៤៥។

[37] *រដ្ឋអាជ្ញា ទល់នឹង Mladić,* MICT-13-56-A, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ Ratko Mladić ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

[38] *រដ្ឋអាជ្ញា ទល់នឹង Karadžić,* MICT-13-55-A, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ Radovan Karadžić ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦។

[39] *រដ្ឋអាជ្ញា ទល់នឹង Popović និងគូកន* IT-05-88-A, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងនាម Milan Gvero ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣។

[40] *រដ្ឋអាជ្ញា ទល់នឹង Sainović និងគូកន* IT-05-87-A, សេចក្តីសន្និដ្ឋានទូទៅរបស់ Pavković អំពីសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩។

[41] *រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងគូកន,* ICTR-98-42-A, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើកទីពីរដែលបានកែប្រែរបស់ Arsène Shalom Ntahobali អនុលោមតាមមាត្រា ២៤ នៃលក្ខន្តិកៈ និងវិធាន ១០៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២។

18. លក្ខខណ្ឌតម្រូវនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅតុលាការ ICTY និងតុលាការ ICTR ស្រដៀងគ្នាទៅនឹងលក្ខខណ្ឌតម្រូវនៃ អ.វ.ត.ក គឺដើម្បី "បញ្ជាក់ពីខ្លឹមសារនៃកំហុសដែលចោទប្រកាន់ និងដំណោះស្រាយដែលស្នើសុំ"[42]។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានលើកឡើង សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ "ចាំបាច់មានតែបញ្ជីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ ដែលបញ្ជាក់យ៉ាងច្បាស់ពីកំហុសដែលបានចោទប្រកាន់ និងដែលកំណត់អត្តសញ្ញាណការសន្និដ្ឋាន ឬការសម្រេចដែលត្រូវជំទាស់ ប៉ុន្តែមិនចាំបាច់រៀបរាប់លម្អិតពីអំណះអំណាងដែលនឹងត្រូវប្រើក្នុងការគាំទ្រដល់ទឡ្ហីករណ៍បណ្តឹងសាទុក្ខឡើយ"។[43]

19. អំណះអំណាងរបស់ ខៀវ សំផន សម្រាប់បន្ថែមទំព័រ មិនបានដកស្រង់អ្វីទាំងអស់ ក្រៅពីទំហំសំណុំរឿង០០២/០២ ធំជាង បើធៀបទៅនឹងសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើរបស់គាត់សុំចំនួនទំព័របន្ថែមនៅក្នុងសំណុំរឿង០០២/០១[44]។ ទោះបីជាកំពុងស្ថិតនៅក្នុងដំណើរការអានសាលក្រម និងមិនទាន់បានកំណត់អត្តសញ្ញាណ ឬរាប់ចំនួនទឡ្ហីករណ៍ដែលគាត់នឹងលើកឡើងក៏ដោយ[45] ក៏ ខៀវ សំផន គិតថា គាត់នឹងត្រូវការ១០០ទំព័រ ជាភាសាបារាំង សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ - ជាចំនួនសរុបដែលច្រើនជាងការកំណត់ចំនួនទំព័រសម្រាប់*សារណាបណ្តឹងសាទុក្ខ* នៅតុលាការអន្តរជាតិផ្សេងទៀតដែរ[46]។

## *(v) ការពិចារណាផ្សេងទៀតដែលបានផ្អែកលើនៅក្នុងសំណើទាំងនោះ*

20. ការអះអាងរបស់ នួន ជា ដែលថាឋានៈរបស់គាត់ និង ខៀវ សំផន ជា "សមាជិកនៅរស់រានជីវិតដែលមានតួនាទី និងឋានៈខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា"[47] ចាំបាច់សក្តិសមនឹងទទួលបានពេលវេលា

---

[42] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី វិធានស្តីពីនីតិវិធី និងភស្តុតាង (វិសោធនកម្ម ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥) វិធាន ១០៨ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វាន់ដា វិធានស្តីពីនីតិវិធី និងភស្តុតាង (វិសោធនកម្ម ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥) វិធាន ១០៨។

[43] សូមមើល *ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Hartmann*, IT-02-54-R77.5-A, សេចក្តីសម្រេចលើញត្តិប្តឹងទាល់ និងសំណើសុំបន្ថែមពាក្យកំណត់ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១២-១៤។

[44] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ៤១។

[45] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ៣៩។

[46] សំមើល *ឧទាហរណ៍* បទបញ្ជារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC-BD/01-05-16 បទបញ្ជាលេខ ៥៨(៥)៖ "ឯកសារគាំទ្របណ្តឹងសាទុក្ខមិនត្រូវលើសពី១០០ទំព័រ"។ តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន សេចក្តីណែនាំអនុវត្តស្តីពីឯកសារនៅការិយាល័យរងនៅ Hague ("សេចក្តីណែនាំអនុវត្ត") មាត្រា៦(ង)(i)៖ "សារណារបស់ម្ចាស់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមមិនត្រូវលើសពី ១០០ទំព័រ ឬ៣០០០០ ពាក្យ មួយណាក៏ដោយដែលច្រើនជាង"។

[47] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ២៨។

និងចំនួនទំព័របន្ថែម ដើម្បីរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនោះ គួរត្រូវបានច្រានចោល។ នួន ជា តែងតែបានព្យាយាមកាត់បន្ថយតួនាទីដែលគាត់មាននៅក្នុង ប.ក.ក[48] ដោយបានតវ៉ានៅក្នុងសារណាសន្និដ្ឋានស្តាពររបស់គាត់ថា តួនាទីរបស់គាត់គឺ "ថ្នាក់ទាប"[49]។ ការណ៍ដែលនៅពេលនេះគាត់ស្នើសុំប្រើសារៈសំខាន់នៃមុខតំណែងរបស់គាត់ ដើម្បីទទួលបានការពន្យារពេលកាលបរិច្ឆេទកំណត់របស់តុលាការ គឺមិនទំនងទៅជាការឈ្លៀតឱកាស។ ជាងនេះទៀត ការលើកឡើងរបស់គាត់ដែលថា រឿងក្តីនេះ "ទំនងជាសំណុំរឿងចុងក្រោយនៅ អ.វ.ត.ក"[50] គឺជាការទាយស្មាន និងមិនពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខបច្ចុប្បន្នឡើយ។

21. ដូចគ្នានេះដែរ ការស្នើឡើងរបស់ ខៀវ សំផន ដែលថា រយៈពេលមួយខែនៃការបន្ថែមពេលវេលាប្រាំបីខែ ដែលបានស្នើសុំ ដើម្បីបកប្រែសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ គួរតែបដិសេធចោល[51]។ ភាពចាំបាច់ក្នុងការបកប្រែសារណា គឺមិនមែនជាករណីលើកលែងសម្រាប់ ខៀវ សំផន ឡើយ។ រាល់ភាគីត្រូវតែធានាថា ការដាក់ឯកសាររបស់ខ្លួនត្រូវបានបកប្រែ ឬស្វែងរកការអនុញ្ញាតពីអង្គជំនុំជម្រះពាក់ព័ន្ធដើម្បីដាក់តែមួយភាសា ដោយមានភាសាផ្សេងទៀតដាក់តាមក្រោយឱ្យបានឆាប់បំផុត[52]។

### *(vi) សំណើររបស់មេធាវីការពារក្តីមិនឆ្លុះបញ្ចាំងពីគោលបំណងនៃបណ្តឹងសាទុក្ខ*

22. សហព្រះរាជអាជ្ញាពិចារណាថា ប្រវែងនៃសាលក្រមមានយុត្តិកម្មចំពោះការបន្ថែមចំនួនពេលវេលាកំណត់ដ៏ច្រើនសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាជឿជាក់ថា ភាគីទាំងអស់ និងអង្គជំនុំជម្រះតុលាការកំពូលទទួលបានអត្ថប្រយោជន៍ នៅពេលដែលភាគីនានាគោរពតាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង និងកំណត់អត្តសញ្ញាណច្បាស់លាស់អំពីកំហុសអង្គច្បាប់ និងអង្គហេតុនីមួយៗ ដែលពួកគេស្វែងរកការជំទាស់[53]។ ជាអកុសល្យ ក្នុងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ ចំណុចនេះមិនត្រូវបានអនុវត្តតាមដោយសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលបានដាក់ដោយ ខៀវ

[48] ឯកសារ **E313** សំណុំរឿង០០២/០១ សាលក្រម កថាខណ្ឌ២៦៤, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, ២៦៤, ៣០៤, ៣១២, ៣៣០, ៣៤២។

[49] ឯកសារ **E457/6/3/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ នួន ជា ដែលបានកែប្រែ កថាខណ្ឌ ១១២៩។

[50] ឯកសារ **F40/1.1** សំណើរបស់ នួន ជា កថាខណ្ឌ២៨។

[51] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣៦, ៤២។

[52] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី៨ ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក មាត្រា ៧(១), (២)។

[53] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) វិធាន ១០៥(៣)។

សំផន នោះទេ[54] ដែលខកខានមិនបានកំណត់អត្តសញ្ញាណឲ្យបានត្រឹមត្រូវចំពោះអង្គហេតុមួយៗ និងកំហុសផ្នែកច្បាប់។ សហព្រះរាជអាជ្ញាយល់ថា ការបន្ថែមរយៈពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ពី៣០ថ្ងៃ ទៅ៧៥ថ្ងៃ គឺមានយុត្តិកម្ម និងថាការកំណត់ចំនួន៣០ទំព័រដែលមានស្រាប់នេះ[55] គួរតែអនុញ្ញាតឲ្យភាគីទាំងអស់បញ្ជាក់បានច្បាស់លាស់ពីកំហុសដែលបានចោទប្រកាន់ ដែលពួកគេជំទាស់។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាយល់ឃើញថា ការបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ដែលបានស្នើសុំដោយ នួន ជា និង ខៀវ សំផន គឺពិតជាច្រើនហួសហេតុពេក ហើយអាចពន្យារពេលកិច្ចដំណើរការនីតិវិធីឥតប្រយោជន៍។

## III. ដំណោះស្រាយដែលស្នើឡើង

23. ផ្អែកតាមអំណះអំណាងខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល (i) បដិសេធសំណើសុំរបស់ នួន ជា និង ខៀវ សំផន ស្នើសុំពេលវេលា និងចំនួនទំព័របន្ថែម និង (ii) អនុញ្ញាតផ្តល់ឲ្យភាគីនូវរយៈពេល៤៥ថ្ងៃបន្ថែម (សរុប៧៥ថ្ងៃ) ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួន ក្នុងចំនួនកំណត់៣០ទំព័រ ដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសាររបស់ អ.វ.ត.ក។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |

[54] សូមមើល *ឧទាហរណ៍* ឯកសារ **F18/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ទំព័រ៤ ត្រង់ចំណុចដែលអង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ថា ខៀវ សំផន "ពុំបានភ្ជាប់ទំនាក់ទំនងរវាងកថាខណ្ឌមួយចំនួនយ៉ាងច្បាស់ក្រឡែតនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ជាមួយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ប៉ុន្តែអំណះអំណាងមួយចំនួន ទំនងជាទំនាក់ទំនងជាមួយនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ"។

[55] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក ស្តីពីការដាក់ឯកសារ មាត្រា ៥(១)។